ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

គណៈកម្មការសុរិយោដីថ្នាក់ជាតិ

លេខ ១៤៥៥ ជនស/គសជ

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីសវនាការ នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អនុលោមតាមអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការកំណត់អំពីនីតិវិធីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដូចតទៅ :

## I.ការចាប់ផ្តើមនៃករណីវិវាទ

១-គណៈកម្មការសុរិយោដីថ្នាក់ជាតិទទួលករណីវិវាទពីគណៈកម្មការសុរិយោដីខេត្ត ក្រុង និងគណៈកម្មការរដ្ឋបាលដែលធ្វើការសម្រុះសម្រួលមិនបានជោគជ័យ ។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរៀបចំទម្រង់បែបបទបញ្ជាក់ពីការទទួលសំណុំរឿងវិវាទដែលបានបញ្ជូនមក ហើយទំរង់បែបបទនេះត្រូវបានរក្សាទុកក្នុងសំណុំរឿងវិវាទ ។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចុះលេខសំណុំរឿងវិវាទ ។

២-លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ពិនិត្យមើលឡើងវិញនូវសំណុំរឿងវិវាទផ្លូវការ ហើយធ្វើកំណត់បង្ហាញឱ្យបានឆាប់បំផុតជូនទៅប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ កំណត់បង្ហាញនេះធ្វើការសំគាល់ថា តើសំណុំរឿងវិវាទមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ឬទេ ហើយថាតើតំរូវឱ្យមានការស៊ើបអង្កេតបន្ថែមដែរ ឬទេ ។

៣-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ប្រសិនបើយល់ថាជាការចាំបាច់ ។ នៅដំណាក់កាលណាមួយនៃដំណើរការវិនិច្ឆ័យមុននឹងធ្វើសេចក្តីសំរេច គណៈកម្មការ



អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659- 215 660 , Fax : (855) 023 215 277, e-mail : im_c_lim @ Camnet.Com.Kh

សុរិយោដីថ្នាក់ជាតិអាចបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ថែមទៀតបាន ។ ការស៊ើបអង្កេតនេះគឺត្រូវធ្វើឡើង ដោយលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

៤-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើការបង្គាប់ផ្សេងទៀតដែលចាំបាច់ទៅលេខាធិការដ្ឋាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីរៀបចំសំណុំរឿងវិវាទឱ្យមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ។

## II. ការរៀបចំដំណើរការករណីវិវាទ

នៅពេលសំណុំរឿងវិវាទមានលក្ខណៈពេញលេញនិងគ្រប់គ្រាន់ហើយនោះ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបញ្ជូនសំណុំរឿងនេះទៅប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីធ្វើការពិនិត្យ ។ ក្រោយពីការពិនិត្យរួច ហើយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចកំណត់ ÷

១-ចំពោះសំណុំរឿងវិវាទដែលចាំបាច់ត្រូវមានការពិភាក្សាផ្ទៃក្នុង ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកអាដហុក (សមាជិកចំពោះកិច្ច) ចូលរួម ។ ការពិភាក្សាផ្ទៃក្នុងនេះជាការពិគ្រោះយោបល់ដើម្បីសំរេចបន្តករណីវិវាទ ឬ ត្រូវច្រានចោលករណីវិវាទតែប៉ុណ្ណោះ ដោយពុំចាំបាច់មានការជូនដំណឹងដល់សាធារណៈជន និងប្រពន្ធ័ផ្សព្វផ្សាយឡើយ ។

២-ចំពោះសំណុំរឿងវិវាទដែលមានពាក្យបណ្តឹងមិនត្រឹមត្រូវឬគ្មានមូលដ្ឋាន ដែលធ្វើឡើងគ្រាន់តែដើម្បីយាយី ឬបំភិតបំភ័យភាគីវិវាទម្ខាង ឬមិនស្ថិតក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី ទោះស្ថិតក្នុងដំណាក់កាលកំពុងដំណើរការក្នុងនីតិវិធីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក៏ដោយ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវសំរេចច្រានចោលសំណុំរឿងវិវាទនោះ ។

៣-ចំពោះសំណុំរឿងវិវាទដែលមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចបង្គាប់ទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីកំណត់អំពីទីកន្លែង និងពេលវេលាដែលនឹងត្រូវរៀបចំសវនាការនៃសំណុំរឿងវិវាទនោះ ។ បន្ទាប់ពីបានទទួលរបាយការណ៍អំពីពេលវេលានិងទីកន្លែងច្បាស់លាស់ដែលត្រូវរៀបចំសវនាការ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវសំរេចបើកសវនាការលើសំណុំរឿងវិវាទនេះ ។

៤-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចបង្គាប់ឱ្យមានការសម្រុះសម្រួលវិវាទបន្ថែមទៀតតាមសំណើរបស់ភាគីវិវាទ ឬតាមការយល់ឃើញរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ នីតិវិធីរដ្ឋបាលនៃការសម្រុះ-សម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈកម្មការសុរិយោដីស្រុក ខណ្ឌដែរ ។ នៅពេលដំណើរការនីតិវិធីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទអាចបដិសេធការចូលរួមរបស់ប្រធាន ឬ សមាជិក រូបណាដែលពាក់ព័ន្ធនឹងវិវាទផលប្រយោជន៍ ។ ប្រធាន ឬសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងវិវាទផលប្រយោជន៍ត្រូវដកខ្លួនចេញពីការដោះស្រាយករណីវិវាទនោះ ហើយរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងប្រធានអាដហុក (ប្រធានចំពោះកិច្ច) ឬសមាជិកថ្មីជំនួសវិញ ។ ក្នុងកំលុងពេលនៃដំណើរការនីតិវិធីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិរហូតដល់ពេលធ្វើសេចក្តីសំរេចលើវិវាទ ភាគីវិវាទនីមួយៗ ឬ តំណាងអាចផ្តល់ឯកសារជា ភស្តុតាង ឬសាក្សីបន្ថែមទៀតក្រៅពីភស្តុតាង និងសាក្សីដែលបានផ្តល់ពីពេលមុន ។

## III. ការជូនដំណឹង និងពេលវេលានៃសវនាការ

### ក-ការជូនដំណឹង

ការជូនដំណឹងអំពីសវនាការត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយកំណត់ច្បាស់លាស់ អំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបើកសវនាការ ។ លិខិតជូនដំណឹងត្រូវប្រគល់ឱ្យដល់ដៃដើមបណ្តឹង ឬតំណាង និង ចុងបណ្តឹង ឬ តំណាង យ៉ាងហោច ១៥ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃបើកសវនាការ ដោយមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកទទួល និងអ្នកប្រគល់លិខិតជូនដំណឹងនោះ ។ ក្នុងករណីភាគីវិវាទណាមួយបដិសេធមិនទទួល ឬ អវត្តមានពីលំនៅដ្ឋានដោយគ្មានមូលហេតុសមស្រប អ្នកប្រគល់លិខិតត្រូវចារលើខ្នងលិខិតបញ្ជាក់ពីមូលហេតុ។

### ខ-ពេលវេលាសវនាការ

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបើកសវនាការចាប់ពីម៉ោង ០៨ : ៣០នាទី ព្រឹក ដល់ម៉ោង ១១ : ៣០ នាទីនៃថ្ងៃធ្វើការ ។ ក្នុងករណីចាំបាច់សវនាការអាចធ្វើនៅម៉ោងផ្សេងពីការកំណត់នេះ ឬអាចបន្តទៅទៀតបាន ។ ការបើកសវនាការអាចដោះស្រាយបណ្តឹងច្រើនករណីបាន ។

### គ-ការបង្ហាញខ្លួននៅពេលសវនាការ

១-ប្រសិនបើភាគីដើមបណ្តឹង ឬ តំណាង បានទទួលលិខិតជូនដំណឹងហើយ តែមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការដោយគ្មានមូលហេតុ ឬ មានមូលហេតុមិនសមស្រប ប្រធានសវនាការត្រូវចេញសេចក្តីសំរេចបញ្ជាក់ពីការបញ្ឈប់ដំណើរការដោះស្រាយ ។

២-ប្រសិនបើភាគីចុងបណ្តឹង ឬតំណាង បានទទួលលិខិតជូនដំណឹងហើយ តែមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការដោយគ្មានមូលហេតុ ឬ មានមូលហេតុមិនសមស្រប ប្រធានសវនាការត្រូវសំរេចករណីវិវាទនេះដោយអវត្តមានចុងបណ្តឹង ឬតំណាង ។

៣-បើភាគីដើមបណ្តឹង ឬ/នឹងចុងបណ្តឹង ស្លាប់មុនពេលសវនាការ អ្នកតំណាងស្របច្បាប់របស់ភាគីនោះអាចចូលរួមក្នុងសវនាការបាន ។

៤-សាក្សីគ្រប់រូបត្រូវមកបង្ហាញខ្លួនចំពោះមុខប្រធានសវនាការតាមការអញ្ជើញ ។

## IV.អំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ គឺជាដំណើរការនៃការប្រជុំរវាងភាគីវិវាទ ( ឬតំណាង ) និងសាក្សី ជាមួយនឹងក្រុមវិនិច្ឆ័យ ឬប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬសមាជិកតែម្នាក់ ឬ មន្ត្រីសវនាការ ដែលរៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីសំរេចទទួលស្គាល់ភោគីស្របច្បាប់ចំពោះដីវិវាទដែលមិនទាន់ចុះបញ្ជីសុរិយោដី ។ សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវធ្វើឡើងជាសាធារណៈ ។

សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចដឹកនាំដោយ :

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ តែ១ រូប ជាប្រធានសវនាការ ឬ

-សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ០១ រូប ដែលត្រូវបានតែងតាំងជាប្រធានសវនាការ ឬ

-មន្ត្រីសវនាការតែ ០១ រូប ដែលត្រូវបានតែងតាំងជាប្រធានសវនាការ ឬ

-ក្រុមវិនិច្ឆ័យមានសមាសភាព ប្រធាន និងសមាជិកមួយរូប ឬសមាជិកទាំងអស់ នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលដឹកនាំដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ជាប្រធានក្រុមវិនិច្ឆ័យ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចរៀបចំឱ្យមានជាសវនាការចល័ត ឬ អចល័ត :

**- <u>សវនាការចល័ត</u>**

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចសំរេចឱ្យមានការធ្វើសវនាការចល័តតាមសំណូមពររបស់ភាគីវិវាទបាន ។ សវនាការចល័តត្រូវធ្វើឡើងនៅលើ ឬជិតទីតាំងដីទំនាស់ ឬកន្លែងណាមួយដែលភាគីវិវាទសំណូមពរ សវនាការចល័តអាចដឹកនាំដោយក្រុមអ្នកវិនិច្ឆ័យ ឬសមាជិកគណៈកម្មការតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបដែលតែងតាំងជាប្រធានសវនាការ ។

**-សវនាការអចល័ត**

សវនាការអចល័តធ្វើឡើងដោយការសំរេចរបស់ប្រធានគណៈកម្មការថ្នាក់ជាតិ ឬ/និងតាមសំណូមពររបស់ភាគីវិវាទ ។ សវនាការអចល័តត្រូវធ្វើនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ សវនាការអចល័ត អាចដឹកនាំដោយក្រុមអ្នកវិនិច្ឆ័យ ឬសមាជិកគណៈកម្មការតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបដែលតែងតាំងជាប្រធានសវនាការ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបើកសវនាការរបស់ខ្លួន តាមរបៀបដូចខាងក្រោមៈ

១-គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើសវនាការជាក្រុមវិនិច្ឆ័យ ឬ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬ សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិតែម្នាក់ ឬ មន្ត្រីសវនាការតែ១រូប ដែលតែងតាំងជាប្រធានសវនាការ ។

២-សវនាការត្រូវប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ប្រធានសវនាការ ។ ប្រធានសវនាការអាចជាប្រធាន ឬសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬមន្ត្រីសវនាការ ដែលចាត់តាំងដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

៣-ក្នុងពេលសវនាការ ប្រធានសវនាការ ត្រូវមានលេខាធិការសវនាការជាជំនួយការ ដែលជាមន្ត្រីលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

## V. ដំណើរការនៃការរៀបចំសវនាការ

របៀបរៀបចំសវនាការត្រូវធ្វើតាមការណែនាំដូចខាងក្រោម ៈ

**ក-លេខាធិការសវនាការ**

លេខាធិការសវនាការមានភារៈកិច្ចដូចតទៅ ÷

-ពិនិត្យ ឬស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងបណ្តឹង ឬតំណាង និងសាក្សី

-អានបទបញ្ជាផ្ទៃក្នុងនៃសវនាការ

-នាំភាគីវិវាទ និងសាក្សីទៅស្បថ

-ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរនៅពេលលេខាធិការសវនាការស្រែកថា "ប្រធានសវនាការ"

-រាយការណ៍ពី វត្តមាន អវត្តមាន អំពីភាគីវិវាទពាក់ព័ន្ធ ជូនប្រធានសវនាការ

-រាយការណ៍ដោយសង្ខេបនូវដំណើររឿងរបស់ករណីវិវាទ

-ត្រូវសរសេរ ឬកត់ត្រាកំណត់ហេតុសវនាការ ។ កំណត់ហេតុសវនាការត្រូវមានហត្ថលេខាអ្នកកត់ត្រា ភាគីវិវាទ និង សាក្សី ។

-អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការស្នើសុំពីប្រធានសវនាការ ។

**ខ-ប្រធានសវនាការ**

-ប្រធានសវនាការត្រូវអង្គុយតាមកន្លែងដែលបានរៀបចំទុក ។

-ប្រធានសវនាការអង្គុយចំកណ្តាល

-សមាជិកអង្គុយអមសងខាង

-លេខាធិការសវនាការត្រូវអង្គុយនៅតុផ្សេងដែលស្ថិតនៅខាងស្តាំដៃប្រធានសវនាការ

ក្រោយពីបានអង្គុយតាមកន្លែងកំណត់រួចមកប្រធានសវនាការត្រូវប្រកាសថា " យើងសូមបើកសវនាការ " រួចត្រូវបន្តសេចក្តីតាមលំដាប់ដូចតទៅ ÷

១-សវនាការនេះត្រូវបានធ្វើឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិទាំងមូល ឬដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬ ដោយសមាជិកតែម្នាក់ ឬដោយមន្ត្រីសវនាការតែមួយរូប ដោយបង្ហាញអំពីឈ្មោះ និងឋានៈរបស់ប្រធានសវនាការ ឬ/និង សមាជិកសវនាការ ព្រមទាំងលេខាធិការសវនាការ លេខសំណុំរឿងករណីវិវាទ ឈ្មោះភាគីវិវាទ ទីតាំងដីវិវាទ និងកម្មវត្ថុនៃវិវាទ ។

**ឧទាហរណ៍ :** ថ្ងៃនេះគណៈកម្មការសុរិយោដីថ្នាក់ជាតិ បើកសវនាការជំនុំជំរះសំណុំរឿងលេខ ................ ចុះថ្ងៃទី..........ខែ...........ឆ្នាំ............ស្ថិតនៅភូមិ.............ឃុំ................ស្រុក................ខេត្ត............ រវាងដើមបណ្តឹងឈ្មោះ.........................................ឬតំណាងឈ្មោះ.................................និងចុងបណ្តឹងឈ្មោះ.....................ឬតំណាងឈ្មោះ........................ ។

២-មូលហេតុនៃការរៀបចំសវនាការ (ដោយហេតុថាករណីវិវាទនេះបានធ្វើការសម្រុះសម្រួល ប៉ុន្តែភាគីវិវាទមិនអាចឈានដល់ការព្រមព្រៀងនៅគណៈកម្មការសុរិយោដីខេត្តក្រុង... ឬគណៈកម្មការរដ្ឋបាលក្នុងតំបន់វិនិច្ឆ័យនៃ ខេត្ត ក្រុងណាមួយ) ។

៣-ប្រធានសួរទៅកាន់លេខាធិការសវនាការថា តើសេចក្តីជូនដំណឹងអំពីសវនាការត្រូវបានផ្តល់ឱ្យភាគីវិវាទទាំងអស់ត្រឹមត្រូវតាមនីតិវិធីដែរឬទេ ? បើសិនជាភាគីវិវាទណាមួយអវត្តមាន តើភាគីវិវាទនោះបានស្នើសុំឱ្យពន្យាពេលសវនាការដែរឬទេ ? បើសិនជាភាគីវិវាទមិនបានធ្វើការស្នើសុំទេ ប្រធានសវនាការអាចធ្វើការសំរេចថា តើត្រូវកំណត់ពេលសវនាការនៅលើកក្រោយ ឬ ធ្វើសវនាការនៅពេលនេះតែម្តង ។ សវនាការមិនអាចដំណើរការដោយអវត្តមានភាគីវិវាទណាមួយឡើយ លើកលែងតែការអវត្តមាននោះគ្មានមូលហេតុ ឬមានមូលហេតុមិនសមស្រប ។

៤-ប្រធានត្រូវឱ្យភាគីវិវាទក្រោកឈរម្នាក់ម្តង១ដើម្បីបង្ហាញអំពីអត្តសញ្ញាណ ហើយត្រូវសួរទៅដើមបណ្តឹងថា ( តើលោក ឬលោកស្រីនៅតែបន្តប្តឹងដូចមានចែងក្នុងកម្មវត្ថុនៃពាក្យបណ្តឹងខាងលើ ឬមានការកែប្រែឬទេ ? ) ប្រសិនបើដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានសវនាការត្រូវបន្តដំណើរការសវនាការ ។

៥-ប្រធានសួរទៅកាន់ភាគីវិវាទថា តើពួកគេមានអ្នកការពារក្តីដែរឬទេ ? បើមានប្រធានត្រូវឱ្យអ្នកការពារក្តីនោះក្រោកឈរឡើង ហើយបង្ហាញអំពីអត្តសញ្ញាណរបស់ខ្លួន ។

៦-ប្រធានសួរទៅកាន់ភាគីវិវាទថាតើមានសាក្សីដែរឬទេ ? តើមានសាក្សីផ្សេងទៀតដែរឬទេ ? បន្ទាប់មកប្រធាន ត្រូវឱ្យសាក្សីទាំងអស់ក្រោកឈរឡើងដើម្បីបង្ហាញអំពីអត្តសញ្ញាណ ។

៧-ប្រធានសួរទៅលេខាធិការសវនាការថា តើសាក្សីទាំងអស់ដែលមានវត្តមាននេះបានធ្វើការស្បថស្បែរ ហើយឬនៅ ? បើមិនទាន់បានស្បថទេ លេខាធិការសវនាការត្រូវនាំសាក្សីទាំងនោះទៅស្បថ ។

៨-ប្រធានសួរទៅកាន់ភាគីវិវាទថាតើមានវត្ថុតាង ឬឯកសារ ដើម្បីផ្តល់ជាភស្តុតាងបន្ថែមផ្សេងទៀត ជូនសវនាការដែរឬទេ ? ប្រធានត្រូវឱ្យភាគីវិវាទបង្ហាញឯកសារ និងវត្ថុតាងទាំងនោះភ្លាមប្រសិនបើមាន ។ បើភស្តុតាងទាំងនោះទាក់ទងទៅនឹងករណីវិវាទពិតប្រាកដ ប្រធានត្រូវឱ្យលេខាធិការសវនាការថតចំលងជាបន្ទាន់ដើម្បីបញ្ចូលក្នុងសំណុំរឿងវិវាទ ។

៩-ប្រធានត្រូវប្រកាសប្រាប់ឱ្យសាក្សីទាំងអស់ថយទៅបន្ទប់រង់ចាំ ឬនៅកន្លែងណាមួយជិតនោះ ប៉ុន្តែមិនអាចស្តាប់ ឮការជជែកដេញដោលក្នុងសវនាការបានឡើយ ។

១០-ប្រធានបង្គាប់ឱ្យលេខាធិការសវនាការអានរបាយការណ៍សង្ខេបអំពីករណីវិវាទ ។ ខ្លឹមសាររបាយកាណ៍មានជាអាទិ៍ ប្រវត្តិករណីដីទំនាស់ ការរកឃើញរបស់អ្នកស៊ើបអង្កេត ជំហរ និងអកប្បកិរិយារបស់ភាគីវិវាទនៅពេលសម្រុះសម្រួល និង សេចក្តីសន្និដ្ឋានរបស់អ្នកសម្រុះសម្រួល ។

១១-ប្រធានបង្គាប់ជាបន្តបន្ទាប់ឱ្យភាគីដើមបណ្តឹង ឬតំណាង និងភាគីចុងបណ្តឹង ឬតំណាង បង្ហាញអំពីគំនិតនិងយោបល់លើករណីវិវាទ ។ ទន្ទឹមនោះប្រធាន ឬ/ និង សមាជិកអាចសួរភាគីវិវាទ ឬតំណាង ហើយភាគីវិវាទ ឬ តំណាងអាចតាំងសំណួរទៅភាគីវិវាទម្ខាងទៀត ឬតំណាងតាមរយៈប្រធានសវនាការ ។

១២-ប្រធាន និង/ឬ សមាជិក អាចសួរសាក្សីរបស់ភាគីដើមបណ្តឹង និង សាក្សីរបស់ភាគីចុងបណ្តឹងឱ្យបំភ្លឺនូវចំណុចមួយចំនួនដែលពាក់ពន្ធ័ ហើយភាគីវិវាទ ឬ តំណាង អាចតាំងសំណួរទៅសាក្សីរបស់ភាគីវិវាទម្ខាងទៀតតាមរយៈប្រធានសវនាការ ។

១៣-សាក្សីដែលឆ្លើយរួចហើយអាចអង្គុយក្នុងបន្ទប់សវនាការ ឬ អាចចាកចេញពីបន្ទប់សវនាការបាន ។

១៤-ប្រធានត្រូវសួរបញ្ជាក់ថាតើនៅមានសាក្សីណាដែលមិនទាន់ត្រូវបានអញ្ជើញមកបំភ្លឺដែរឬទេ ?

១៥-នៅពេលដែលភាគីវិវាទ ឬតំណាង និងសាក្សី បញ្ចប់សក្តីកម្ម ប្រធានបង្គាប់ឱ្យភាគីវិវាទ ឬតំណាងបង្ហាញអំពីជំហររបស់ភាគីវិវាទចំពោះករណីវិវាទ ។

១៦-ក្រោយពីបានដំណើរការតាមលំដាប់រួចហើយ ប្រធាន និងសមាជិក( ករណីសវនាការធ្វើជាក្រុម) ឬប្រធាន ( ករណីសវនាការធ្វើឡើងដោយប្រធាន ឬ សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬមន្ត្រីសវនាការតែម្នាក់ ) ត្រូវថយទៅពិចារណាករណី នោះនៅបន្ទប់ដែលបានរៀបចំដោយឡែក ។

១៧-ក្រោយពេលពិចារណាប្រធានត្រូវធ្វើការប្រកាសថា ÷

-សវនាការនឹងធ្វើការសំរេចលើករណីវិវាទនាពេលនេះតែម្តង ឬ

-សវនាការមិនអាចធ្វើការសំរេចលើករណីវិវាទ នាពេលនេះបានឡើយដោយហេតុថា ប្រធានសវនាការត្រូវការ ពេលវេលាបន្ថែមទៀតដើម្បីពិចារណា ។ សេចក្តីសំរេចនឹងត្រូវធ្វើជូនភាគីវិវាទនៅពេលក្រោយ ។ ភាគីវិវាទ មានសិទ្ធិប្តឹងទៅតុលាការក្នុងករណីដែលពុំសុខចិត្តនឹងការសំរេច ឬ អាចស្នើសុំធ្វើសវនាការសារជាថ្មីនៅពេលដែលភាគីវិវាទមានភស្តុតាងថ្មីធំដុំដាក់ជូនមកគណៈកម្មការសុរិយោដីថ្នាក់ជាតិក្នុងរយៈពេល ៤

៣០ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួលសេចក្តីសំរេចនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

១៨-ការធ្វើសវនាការឡើងវិញត្រូវអនុវត្តនីតិវិធីសវនាការដូចពេលមុនដែរ ។ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិបដិសេធចំពោះសំណើសុំឱ្យមានសវនាការឡើងវិញនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនេះដល់ភាគីវិវាទ ។ នៅក្នុងករណីនេះ សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល ៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធ ត្រូវបានបញ្ជូនដល់ភាគីវិវាទ លើកលែងតែភាគីម្ខាង នៃភាគីវិវាទ ជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹង ពីការបដិសេធចំពោះសំណើនោះ ។

១៩-ប្រធានធ្វើការពន្យល់ទៀតថា នៅពេលដែលសេចក្តីសំរេចនោះចូលជាស្ថាពរហើយ គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងធ្វើសេចក្តីសំរេចនោះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដើម្បីចាត់ការតាមនីតិវិធីនៃការចុះបញ្ជីសុរិយោដី ។

២០-នៅចុងបញ្ចប់នៃសវនាការប្រធានត្រូវប្រកាសថា " បិទសវនាការ " ។

## VI. របៀបនៃការធ្វើសេចក្តីសំរេច

១- សេចក្តីសំរេចទៅលើករណីវិវាទណាមួយរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវសំរេចដោយ ÷

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ តែ ១ រូប

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ១រូប ហើយសេចក្តីសំរេចត្រូវធ្វើឡើងដោយសំឡេងជាឯកច្ឆ័ន្ទ ។ ក្នុងករណីមិនឯកភាពគ្នា ប្រធានមានឧត្តមានុភាព ។

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ២រូប ហើយសេចក្តីសំរេចត្រូវធ្វើឡើងដោយសំឡេងភាគច្រើន ។ ក្នុងករណីមិនអាចរកសំឡេងភាគច្រើនបាន ប្រធានមានឧត្តមានុភាព ។

២-សេចក្តីសំរេចទាំងអស់ ត្រូវធ្វើតាមទំរង់បែបបទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

## VII. របៀបនៃការសំរេចក្នុងការធ្វើសវនាការឡើងវិញ

១-សំណើសុំឱ្យមានសវនាការឡើងវិញត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងកំលុងពេល ៣០ថ្ងៃ បន្ទាប់ពីភាគីវិវាទបានទទួលសេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ សំណើសុំឱ្យមាន

សវនាការឡើងវិញត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់នូវព័ត៌មាន ភស្តុតាងថ្មីធំដុំ និងគំនូសតាងចាំបាច់នានា ។

២-ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេលើកលែងតែមានសំឡេងយល់ព្រមពីសមាជិកទាំងអស់នៃគណៈ-កម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលភស្តុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

៣-ការធ្វើសវនាការឡើងវិញត្រូវអនុលោមទៅតាមសេចក្តីជូនដំណឹង និងលក្ខខណ្ឌតំរូវផ្នែកនីតិវិធីដូចសវនាការដើមដែរ ។

៤-ក្នុងករណីបណ្តឹងសុំធ្វើសវនាការឡើងវិញត្រូវបានបដិសេធ នោះគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវជូនដំណឹងដល់ភាគីវិវាទជាលាយលក្ខណ៍អក្សរពីមូលហេតុនៃការបដិសេធនេះ។ នៅក្នុងករណីនេះ សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនដល់ភាគីវិវាទ លើកលែងតែភាគីម្ខាងនៃភាគីវិវាទជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការក្នុងរយះពេល៣០ថ្ងៃបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីការបដិសេធចំពោះសំណើនោះ ។

## VIII.បណ្តឹងជំទាស់ទៅតុលាការ

១-ភាគីវិវាទណាក៏ដោយអាចប្តឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការ ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ ។ ភាគីវិវាទណាមួយដែលធ្វើបណ្តឹងទៅតុលាការត្រូវដាក់តំកល់ឯកសារថតចំលងមួយច្បាប់ នៃបណ្តឹងជំទាស់នៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីភាគីនោះបានទទួលសេចក្តីសំរេចពីគណៈ-កម្មការសុរិយោដីថ្នាក់ជាតិ។

២-លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើសេចក្តីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការដើម្បីបញ្ជូនទៅតុលាការ ។

៣-ក្នុងករណី តុលាការបញ្ជូនករណីវិវាទមកគណៈកម្មការសុរិយោដីថ្នាក់ជាតិវិញដោយហេតុថា គណៈកម្មការសុរិយោដី មិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទផលប្រយោជន៍ ឬដោយមិនបានផ្តល់ហេតុផលសមរម្យ ឬ ដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដីត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ ។

## IX. បទបញ្ជាផ្ទៃក្នុងពេលសវនាការ

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខ ក្នុងបន្ទប់សវនាការ ជនគ្រប់រូប ដែលមានវត្តមាន ក្នុងបន្ទប់សវនាការត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ ÷

១-ហាមជក់បារីក្នុងបន្ទប់សវនាការ ឬកន្លែងប្រជុំសម្រេច

២-ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់សវនាការ ឬកន្លែងប្រជុំសម្រេចដូចជា

-ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត

-ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ មាន សម្លេងទូរស័ព្ទ ឬសម្លេង ឧបករណ៍ផ្សេងៗជាដើម ។

៣-ហាមយកក្មេងអាយុក្រោម ១៨ ឆ្នាំ ចូលក្នុងបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពី ប្រធានសវនាការ ។

៤-ហាមយកអាវុធគ្រប់ប្រភេទ ជាតិផ្ទុះ សារធាតុពុល និងវត្ថុបង្កគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងបន្ទប់ សវនាការ ។

៥-ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានសវនាការ ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលសវនាការ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

## X. នីតិវិធី និងខ្លឹមសារនៃសម្បថ

ភាគី និងសាក្សីត្រូវធ្វើសម្បថ និងឆ្លើយបំភ្លឺជូនប្រធានសវនាការ ។ ក្នុងករណីភាគី និងសាក្សីឆ្លើយកុហក ឬបំផ្លើសពីការពិតនឹងត្រូវផ្តន្ទាទោសតាមច្បាប់ ។

នីតិវិធីនៃការធ្វើសម្បថ និងខ្លឹមសារ នៃសម្បថមានដូចខាង ក្រោម ÷

១-<u>នីតិវិធីនៃសម្បថ</u>

សម្បថត្រូវធ្វើឡើងដូចខាងក្រោម ÷

-សម្បថរបស់ភាគី និងសាក្សីត្រូវធ្វើមុនពេលសាកសួរ ឬការឆ្លើយបំភ្លឺ ។

-មុនពេលធ្វើសម្បថ លេខាធិការសវនាការត្រូវពន្យល់អំពីគោលបំណងនៃសម្បថ និងប្រាប់ឱ្យដឹងជាមុន អំពីទុក្ខទោស នៃការក្លែងបន្លំពាក្យសម្បថ ។

-នៅពេលធ្វើសម្បថ ភាគី និងសាក្សីត្រូវក្រោកឈរឡើងហើយត្រូវធ្វើការស្មិងស្មាធិ

-លេខាធិការសវនាការត្រូវឱ្យភាគី និងសាក្សី អានលិខិតសម្បថ ហើយត្រូវឱ្យចុះហត្ថលេខាលើលិខិតនោះផង ។ នៅពេលដែលភាគី និងសាក្សីមិនអាចអានលិខិតសម្បថបានទេ លេខាធិការសវនាការត្រូវអានសម្បថនោះរួចឱ្យភាគី និងសាក្សីថាតាម បន្ទាប់មកឱ្យភាគី និងសាក្សីផ្តិតមេដៃលើលិខិតសម្បថនេះ ។

២-ខ្លឹមសារនៃពាក្យសម្បថ

ពាក្យសម្បថត្រូវមានខ្លឹមសារដូចខាងក្រោម :

**សម្បថ**

យើងទាំងអស់គ្នា សូមស្បថចំពោះមុខព្រះអង្គដងកើ លោកយាយទេពដងកើ ទេព្តាថែរក្សាព្រះមហាស្វេតច្ឆ័ត្រ លោកមេទ័ពសេះសរក្សាក្នុងរាជវាំង ព្រះអង្គវិហារសួគ៌ ព្រះអង្គគោកធ្លក ព្រះនាងចេក ព្រះនាងចម សូមលោកអញ្ជើញលោកតាព្រះចៅ លោកតាដំបងក្រញូង លោកតាក្រហមក លោកតាក្បាលប្រាំបីរក្សាក្បាលជ្រោយ បើយើងខ្ញុំសច្ចានេះមិនស្មោះត្រង់ មានចិត្តវៀចវេរ សូមឱ្យព្រះអង្គដាក់ទោសតាមពាក្យសម្បថដូចខាងក្រោមនេះ

-បើយើងខ្ញុំនៅផ្ទះឱ្យធ្លាក់ពីលើផ្ទះ ឬរអិលដួលស្លាប់ប្រាំបីរយជាតិ បើយើងខ្ញុំជិះទូកកប៉ាល់សូមឱ្យធ្លាក់ទឹកលង់ស្លាប់ប្រាំបីរយជាតិ បើយើងខ្ញុំស្លាប់ទៅជាខ្មោចសូមឱ្យស៊ីខ្ទុះឈាម ឬ ហែលនៅក្នុង ខ្ទះភ្លើងប្រាំបីរយជាតិ បើកើតមកជាមនុស្ស សូមឱ្យជួបតែក្រខ្វះខាតគ្រប់ប្រាំបីរយជាតិ និងសូមឱ្យបារមីគ្រប់ព្រះអង្គបរាមុខ និងវាយបំបាក់កគ្រប់ប្រាំបីរយជាតិ ។

-បើយើងខ្ញុំមានការទៀងត្រង់ សូមវត្ថុសក្តិសិទ្ធិគ្រប់ទិសទី និងទេព្តារក្សាទិសទាំងប្រាំបី ជួយឱ្យយើងខ្ញុំទាំងអស់ជួបតែសេចក្តីសុខគ្រប់ប្រការ បើខ្ញុំស្លាប់ពីជាតិនេះ អន្ទោលទៅកើតក្នុងភពធំ ឬភពតូចណាក្តីសូមបានជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានបញ្ញាស្មារតីឆ្លាតវៃ កុំឱ្យស្គាល់សេចក្តីក្រលំបាក ជម្ងឺដង្កាត់ជារៀងរាល់ជាតិ រហូតដល់បានសម្រេចព្រះនិព្វានជាឋានបរមសុខនោះហោង ។

យើងខ្ញុំសូមស្បថថា និងបរិយាយការពិតដោយយោលទៅតាមមនសិការ មិនលាក់រឿងអ្វីទាំងអស់ និងមិនបន្ថែមបន្ថយរឿងអ្វីឡើយ ។

ដោយករណីនេះ ជានីតិវិធីថ្មីដំបូងពុំធ្លាប់បានអនុវត្តកន្លងមកនោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចធ្វើការកែសំរួលក្នុងពេលកំពុងអនុវត្ត ឬ អាចអនុវត្តដោយពុំតម្រូវតាមនីតិវិធីមួយចំនួនជាបណ្តោះអាសន្ននិងជំនួសដោយនីតិវិធីដែលពុំមានចែង តែជាការចាំបាច់ដើម្បីចៀសវាងការកកស្ទះការងារ ។

សេចក្តីណែនាំនេះអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលីម

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្តក្រុង
- គ្រប់គណៈកម្មការសុរិយោដីខេត្ត ក្រុង
- អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- មន្ទីរដនសស.ខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ